ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

១១១១១១១១១

តុលាការកំពូល

សាខាផ្នែក ព្រហ្មទណ្ឌ

- - - - - - - - - -

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ២៣

ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ១៩៩៨

សាលដីកា

លេខ : ២៥

ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ១៩៩៨ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | | |
|---|---|---|---|
| ១ - ឯកឧត្តម | ឌិត | មុន្ទី | ប្រធាន |
| ២ - លោក | យឹម | ស៊ីផល | ចៅក្រម |
| ៣ - លោក | សោម | សិរីវឌ្ឍ | ចៅក្រម |
| ៤ - លោក | ប្រាក់ | គឹមសាន | ចៅក្រមជួយការងារ |
| ៥ - លោក | យស់ | សូខឡឺន | ចៅក្រម |
| លោក | ទេព | វ៉ាន់ថន | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

លោក ដួន ស៊ុនទៀង ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

ពីបទ : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ចុះថ្ងៃទី ១០.៩.១៩៩២ ។

-ជនជាប់ចោទឈ្មោះ គីម វណ្ណធី "ជាចុងបណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ៣៥ ឆ្នាំ ជាតិ ខ្មែរ កើតនៅឃុំកៀនទីជ្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម របររកស៊ីនិស្សិតពេទ្យ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៦៥ ផ្លូវសហភាពសូវៀត ភូមិចុងថ្នល់កើត សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ គីម ឡេញ "ស" ម្តាយឈ្មោះ អ៊ឹម ម៉េង "រ" ប្រពន្ធឈ្មោះ សោម ចាន់ធី មានកូន០១នាក់ ។ ក្នុងឃុំ ។

- ទោសាទី គ្មាន

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស៊ុង មុយហេង " ជាម្ចាស់បណ្ដឹងសាទុក្ខ " ភេទស្រី អាយុ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល របររកស៊ីលក់ដូរ មានទីលំនៅលេខផ្ទះលេខ ៧៦អឺ១ ក្រុម ១៥ ផ្លូវ ១៩៩ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ថេង មែងស៊ុង "ស" ម្ដាយឈ្មោះ លាង គ្រុយ "រ" ប្ដីឈ្មោះ យោង អៀក មានកូន ០១ នាក់ ។

មេធាវី គ្មាន

- តាមបណ្ដឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៨ របស់អ្នកស្រី ស៊ុង មុយហេង ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

- តាមរបាយការណ៍ ចុះថ្ងៃទី ១៥.៣.៨៧ របស់នគរបាលខណ្ឌឫស្សីកែវ ឈ្មោះ អ៊ុយ វណ្ណឌី បានឆ្លើយថា : បានជាសមត្ថកិច្ចធ្វើការឃាត់ខ្លួន មកពីខ្លួនឆបោកប្រាក់ឈ្មោះ ស៊ុង មុយហេង ដែលមានចំនួនទឹកប្រាក់ ៣ ១០០ ០០០បាត និង ១៨០០០ដុល្លារ ។ ការរកស៊ីរវាងឈ្មោះ ស៊ុង មុយហេង និង ខ្លួន មានការទុកចិត្តគ្នា ឈ្មោះ ស៊ុង មុយហេង ក៏បង្វិលលុយកាន់តែច្រើនឡើង. រហូតដល់ ៣ ៣៩០ ០០០បាត និង ៣៣០០០ ដុល្លារមកអោយខ្លួន ដោយគិតថា ការបង្វិលលុយកាន់តែច្រើនទៅៗ នៅថ្ងៃទី ២៣.១១.៨៦ វេលាម៉ោង ៩ ឈ្មោះ ស៊ុង មុយហេង បិទបញ្ជីអោយខ្លួនធ្វើការទូទាត់លុយម្ដង ខ្លួនក៏គេចខ្លួនមកភ្នំពេញ ដោយលេងល្បែងនៅ ប៉ូលីវេ និង ពិភពលោក ២ ចាញ់អស់គ្មានលុយសងមកឈ្មោះ ស៊ុង មុយហេងទេ ។

- តាមពាក្យបណ្ដឹង ចុះថ្ងៃទី ១៤.៣.៨៧ របស់ឈ្មោះ ស៊ុង មុយហេង ជាដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លើយថា : កាលពីថ្ងៃទី ៣០.១០.៨៥ ជនល្មើសឈ្មោះ អ៊ុយ វណ្ណឌី បានមកដកយកប្រាក់ក្រុមហ៊ុនខ្លួន ថាយកទៅអោយក្រុមហ៊ុនផ្សេងទៀត តែក្រោយមក ឈ្មោះនេះគេចខ្លួនពុំព្រមយកលុយសងក្រុមហ៊ុនខ្លួនវិញឡើយ។ ចំនួនទឹកប្រាក់នោះគឺ ៣ ១០០ ០០០បាត និង ១៨ ០០០ដុល្លារ ។ ខ្លួនប្ដឹងទាមទារមកវិញ និង សុំអោយតុលាការផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញថា : សំរេចចោទប្រកាន់លើឈ្មោះ អ៊ុយ វណ្ណឌី ភេទប្រុស អាយុ ៣២ ឆ្នាំ ពីបទរំលោភលើសេចក្ដីទុកចិត្ត នៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ២៣.១១.៨៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា - ៤៦ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦១ "ខ" ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ១៩៨៧ របស់ តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១ - ផ្ដន្ទាទោសឈ្មោះ អ៊ុយ វណ្ណឌី ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា របររកស៊ីនិស្សិតពេទ្យ ទីលំនៅផ្ទះលេខ ៦៥ ផ្លូវសហភាពសូវៀត ភូមិបឹងថ្មល់កើត សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ប្រពន្ធឈ្មោះ សោមចាន់ធី មានកូន ០១នាក់ ឪពុកឈ្មោះ អ៊ុយ ឡេញ "ស" ម្ដាយឈ្មោះ អ៊ីវ ម៉េង "រ" ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទរំលោភលើសេចក្ដីទុកចិត្ត បទល្មើសដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញ

កាលពីថ្ងៃទី ២៣.១១.៨៦ ។

២- អោយឈ្មោះ អ៊ុយ វណ្ណធី សងប្រាក់ចំនួន ៣ ១០០ ០០០រៀល និង ប្រាក់ដុល្លា ១៨ ០០០ ដុល្លា ព្រមទាំងជម្ងឺចិត្ត ៥ ម៉ឺនរៀល ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ សុង មុយហេង ។ ក្នុងករណីឈ្មោះ អ៊ុយ វណ្ណធី នឹងរួចមិនព្រមសង ត្រូវជាប់គុកបង្ខំលើរូបកាយចំនួន ២ ឆ្នាំ ដើម្បីទារប្រាក់ខាងលើ តាមបញ្ញត្តិមាត្រា ៣.៧ និង ១០ នៃច្បាប់ស្ដីពីការជាប់គុកបង្ខំលើរូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

៣- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខភក្ដី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៣២ "ខ" ចុះថ្ងៃទី ០៨ ខែតុលា ឆ្នាំ១៩៨៧ របស់ លោក-សោម ចាន់ឌីណា មេធាវី ការពារអោយជនជាប់ចោទឈ្មោះ អ៊ុយ វណ្ណធី ដែលប្ដឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៦១ "ខ" ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ១៩៨៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា : រឿងនេះខ្លួនយល់ថា ការរកស៊ីរវាងជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី គឺជារឿងពាណិជ្ជកម្ម ដូច្នេះ រឿងនេះ ជារឿងពាណិជ្ជកម្ម ត្រូវតែតុលាការរដ្ឋប្បវេណីជាអ្នកដោះស្រាយ ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨.១០.៨៧ របស់លោក សោម ចាន់ឌីណា មេធាវីជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៦១ "ខ" ចុះថ្ងៃទី ១៦.៩.៨៧ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣- សំរេចអោយឈ្មោះ អ៊ុយ វណ្ណធី បានរួចផុតពីបទចោទ ស្ដីពីបទកេងប្រវ័ញ្ចទំនុកចិត្ត ដែលតុលាការក្រុងភ្នំពេញ បានសំរេចផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- បង្គាប់អោយដោះលែងឈ្មោះ អ៊ុយ វណ្ណធី កាលបើពុំមានជាប់ខ្លួន ពីបទល្មើសផ្សេងទៀតទេ ។

៥- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៨ របស់អ្នកស្រី សុង-មុយហេង ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញ សារណា ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ១៩៨៨ របស់អ្នកស្រី សុង មុយហេង ជាម្ចាស់បណ្ដឹងសាទុក្ខផ្ញើទៀងក្នុងកំណត់ច្បាប់ ។

- បានឃើញ សារណាឆ្លើយតប ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ១៩៨៨ របស់ឈ្មោះ អ៊ុយ វណ្ណធី

ជាចុងបណ្ដឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្ដាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់ សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូលថា ៖

១ - បណ្ដឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ០២.៤.៨៨ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

២ - សាលដីកាព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី ០៦.៤.៨៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

ហេតុដូច្នេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់តទៅ ។

- បានស្ដាប់ ចម្លើយអះអាងរបស់អ្នកស្រី សុង មុយពេង ជាម្ចាស់បណ្ដឹងសាទុក្ខនៅពេលជំនុំជំរះថា ៖ មូលហេតុនាំឲ្យប្ដឹងសាទុក្ខ មកពីសាលាឧទ្ធរណ៍សំរេចសេចក្ដីពុំត្រឹមត្រូវ នាងខ្ញុំសូមបដិសេធសេចក្ដីសំរេចនេះ - ចោល ហើយសូមតម្កល់សាលក្រមរបស់តុលាការក្រុងទុកជាបានការអោយនាងខ្ញុំដោយអនុគ្រោះ ។

- បានស្ដាប់ ចម្លើយដោះសារបស់ឈ្មោះ អ៊ុយ វណ្ណធី ជាចុងបណ្ដឹងសាទុក្ខនៅពេលជំនុំជំរះថា ៖ ខ្ញុំបាទពិតជាបានជំពាក់ប្រាក់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៥០ ម៉ឺនបាតមែន គឺលើកទី ១ ខ្ញុំបានខ្ចី ១៥ ម៉ឺនបាត - លើកទី ២ ខ្ញុំបានខ្ចី ១៥ ម៉ឺនបាត និង លើកទី ៣ ខ្ញុំបានខ្ចី ២០ ម៉ឺនបាត ខ្ញុំនឹងសងមិនគេចខ្លួនឡើយ ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទៅ ប៉េអឹម ចាប់ខ្លួនខ្ញុំតែម្ដង ។ ខ្ញុំបាទជានិស្សិតពេទ្យ ត្រូវការប្រលងបញ្ចប់យក - សញ្ញាបត្រ ដូច្នេះ សូមតុលាការមេត្តាពិចារណាផង ។

- បានស្ដាប់ សេចក្ដីសន្និដ្ឋានបន្ថែមនៅពេលវេនាការ របស់តំណាងមហាអយ្យការ អម តុលាការកំពូលថា ៖ ពិតជាមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ សុង មុយពេង និង ឈ្មោះ អ៊ុយ វណ្ណធី ពិតជាបានរកស៊ីប្រគល់លុយទៅវិញទៅមកប្រាកដមែន ប៉ុន្តែឈ្មោះ អ៊ុយ វណ្ណធី យកលុយមិនមែនជារបស់ខ្លួនទៅលេងល្បែងបាញ់ ។ ដូច្នេះ សូមតុលាការសំរេចតាមច្បាប់ ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនិងរបស់ជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៥ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៨ របស់ អ្នកស្រី សុង មុយពេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយឈ្មោះ អ៊ុយ វណ្ណធី រួចផុតពីបទរំលោភលើទំនុកចិត្ត ដោយអាងហេតុថា ជាសកម្មភាពពាណិជ្ជកម្មដើម្បីទទួលយកផលចំណេញរៀង ៗ ខ្លួននោះ -

ជាការភ័ន្តច្រឡំពីព្រោះថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណីពិតជាបានព្រមព្រៀងគ្នា បង្វិលប្រាក់ដោយដើមបណ្ដឹងរដ្ឋប្បវេណីផ្ញើប្រាក់ទៀតពីភ្នំពេញ ទៅអោយជនជាប់ចោទនៅប៉ោយប៉ែត ហើយជនជាប់ចោទត្រូវបង្វិលប្រាក់ដែលផ្ញើបាន មកអោយដើមបណ្ដឹងរដ្ឋប្បវេណីវិញនៅភ្នំពេញ ។ ប៉ុន្តែជនជាប់ចោទ ពុំបានបំពេញការកិច្ចរបស់ខ្លួន ហើយបានយកប្រាក់នេះទៅប្រើប្រាស់ខុសទិសដៅកំណត់ ដោយយកទៅលេងល្បែងស៊ីសង ធ្វើអោយខាតបង់ផលប្រយោជន៍ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចចម្លើយរបស់ជនជាប់ចោទ នៅចំពោះមុខតុលាការថ្នាក់ក្រោម អំពើនេះជាបទល្មើសព្រហ្មទណ្ឌ ដែលមានធាតុ និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៧ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងអង្គច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី និង ជនជាប់ចោទ

១ - ទទួលបណ្ដឹងសារទុក្ខលេខ ១៥ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៩៧ របស់អ្នកស្រីសុង ម៉ុយហេង ទុកជាត្រឹមត្រូវតាមទំរង់ និង អង្គច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ៦៧ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៨ ។